**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ.....០៣១.....ស.ប៧

ថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ២០១៨

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ប្រធាន**

**អង្គភាពថ្នាក់កណ្តាល រាជធានី-ខេត្ត និងម្ចាស់សេវាឯកជន**

**កម្មវត្ថុៈ** សំណើសុំកិច្ចសហការក្នុងការស្រង់ព័ត៌មានពាក់ព័ន្ធនឹងសម្បទា និងគុណវុឌ្ឍិក្នុងការប្រកបវិជ្ជាជីវៈ របស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។

**យោងៈ**
- ព្រះរាជក្រម លេខនស/រកម/១១១៦/០១៨ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- ព្រះរាជក្រឹត្យ លេខនស/រកត/០២០០/០៣៩ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ
- ព្រះរាជក្រឹត្យ លេខនស/រកត/០៨០៥/៣៩៦ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា
- ព្រះរាជក្រឹត្យ លេខនស/រកត/០៩០៦/៣៨៩ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈឆ្មបកម្ពុជា
- ព្រះរាជក្រឹត្យលេខនស/រកត/០៨០៧/៣៧៣ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា
- ព្រះរាជក្រឹត្យ លេខនស/រកត/០២១០/១៦២ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការបង្កើតគណៈឱសថការីកម្ពុជា

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបថា គណៈវិជ្ជាជីវៈសុខាភិបាលទាំង៥ ដែលមានៈ ១.គណៈគ្រូពេទ្យ ២.គណៈទន្តពេទ្យកម្ពុជា ៣.គណៈឆ្មបកម្ពុជា ៤. គណៈគិលានុបដ្ឋាកកម្ពុជា ៥.គណៈឱសថការីកម្ពុជា មានការចាំបាច់ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព និងគុណភាពកាន់តែល្អប្រសើរក្នុងការផ្តល់សេវាសុខាភិបាល និងអនុលោមតាមមាត្រាទី១៩នៃព្រះរាជក្រមស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ដែលតម្រូវឲ្យគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធធ្វើការត្រួតពិនិត្យសម្បទាអ្នកប្រកវិជ្ជាជីវៈសុខាភិបាលទាំងអស់ ទាំងសេវាសាធារណៈ និងឯកជន ក្នុងព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ លោកស្រី អស់លោក បង្កលក្ខណៈងាយស្រួលឲ្យគណៈវិជ្ជាជីវៈសុខាភិបាលទាំង៥ បានបំពេញភារកិច្ចស្រង់ព័ត៌មានសំខាន់ៗ ជុំវិញគុណវុឌ្ឍិ និងសម្បទាវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់មានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋលេខាធិការក្រសួងសុខាភិបាល**

**និងជាប្រធានគណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាល**

សាស្ត្រាចារ្យ ឆា-គ្រួយ